# *សិលាចារឹកទួលបល្ល័ង្ក (វត្តប្រណ្ហូក) ខេត្តកំពង់ឆ្នាំង* K.1418

*ទួលបល្ល័ង្ក មានទីតាំងស្ថិតនៅភូមិឯលិច ឃុំប្រណ្ហូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលមានចម្ងាយត្រឹមតែ ៣៥០ម៉ែត្រ ខាងលិចប្រាសាទភ្នំពណ្ណរាយ។ បុរាណដ្ឋានទួលបល្ល័ង្ក បានបាក់បែកស្ទើរទាំងស្រុងទៅហើយ (នៅសល់តែគ្រឹះ) ប៉ុន្តែនៅរវាងពីរទសវត្សរ៍មុនគេបាន ប្រទះឃើញសិលាចារឹកចំនួន ១ ផ្ទាំង។ បន្ទាប់មក ព្រះសង្ឃ គណៈកម្មការវត្ត និងអ្នកស្រុក បាន ឯកភាពគ្នា បញ្ជូនសិលាចារឹកនេះយកមករក្សាទុកនៅវត្តសិរីរតនារាម ហៅវត្តប្រណ្ហូក រហូតមក ទល់សព្វថ្ងៃ។ កន្លងមក មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង ធ្លាប់បានស្នើសុំយកសិលា ចារឹកនេះមករក្សាទុក និងដាក់តាំងបង្ហាញនៅសារមន្ទីរខេត្តកំពង់ឆ្នាំង ប៉ុន្តែ ព្រះសង្ឃ គណៈ កម្មការវត្ត និងអ្នកស្រុក មិនយល់ព្រមតាមសំណើនេះឡើយ ទើបសព្វថ្ងៃសិលាចារឹកនេះនៅតែ ស្ថិតនៅក្នុងបរិវេណវត្តប្រណ្ហូក (ក្បែរខឿនព្រះវិហារ)។ តើសិលាចារឹករកឃើញនៅបុរាណដ្ឋាន ទួលបល្ល័ង្ក ខេត្តកំពង់ឆ្នាំង មានខ្លឹមសារ និងអត្ថន័យដូចម្ដេចខ្លះ?*

*សិលាចារឹកនេះ ចារឹកនៅលើថ្មភក់នៃមេទ្វារប្រាសាទ មានផ្ទៃគគ្រើម (រំលីងមិនទាន់បាន ល្អ) សរសេរជាភាសាសំស្ក្រឹត មានអក្សរចំនួន ២៤បន្ទាត់ ស្មើនឹង ១២ស្លោក តាមកំណាព្យសំស្ក្រឹត បែបអនុស្ដុបឆន្ទ។ សិលាចារឹកនេះ ចារឹកឡើងនៅស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទឝ្រីឥឝានវម៌្ម(ទី១) (គ.ស.៦១៦ - ៦៣៧) ដែលជាស្ថាបនិកទីក្រុងឦសានបុរ (សំបូរព្រៃគុក)។*

*ផ្នែកខាងដើមរបស់សិលាចារឹក (ស្លោកទី១) ពណ៌នាអំពីព្រះសិវ ជា "**វិភ្ជេគ**" ដែលមានន័យ ថា ជាអ្វីៗគ្រប់យ៉ាងរបស់លោកធាតុក្នុងចក្រវាឡ ដែលរួមបញ្ចូលមកត្រឹមតែ ៨ ចំណែក ហៅថា "**អឞ្ដមូត្តិ**" ឬរាងកាយមាន ៨ ចំណែក។ បើតាមគម្ពីរលិង្គបុរាណ បានចែងថា អឞ្ដមូត្តិ (អស្ដមូត្តិ) នៃ ព្រះកាយព្រះសិវ រួមមាន សវ៌, ភវ, បសុបតិ, ឦសាន, ភីម, រុទ្រ, មហាទេវ, ឧគ្រ។ ពាក្យ "អឞ្ដមូត្តិ" នេះ គេធ្លាប់ឃើញមាននៅក្នុងសិលាចារឹកបុរាណខ្មែរជាច្រើន ទាំងសម័យមុនអង្គរ និងអង្គរ។ ឧទាហរណ៍ សិលាចារឹកភ្នំព្រះវិហារ ខេត្តកំពង់ឆ្នាំង (K.733) ដែលស្ថិតនៅមិនឆ្ងាយពីទួលបល្ល័ង្ក ដែរនោះ បានរៀបរាប់ថា ទម្រង់ទាំង៨ (អស្ដមូត្តិ) នៃព្រះសិវ រួមមាន ឥន្ទុ (ព្រះចន្ទ្រ), រវិ (ព្រះ អាទិត្យ), វ្យោម (អាកាស), វាយុ (ខ្យល់), អាត្ម (អាត្ម័ន), ជគត (ផែនដី), ទឹក, ភ្លើង។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

*ចូលមកដល់ ស្លោកទី២ សិលាចារឹកបានពណ៌នាអំពីគោលនយោបាយចំនួន ២ យ៉ាង របស់ព្រះបាទស្រីសានវម៌្ម (ទី១) ដើម្បីបញ្ចប់សង្គ្រាម និងនាំឱ្យស្រុកទេសមានសន្តិភាព ពោល គឺ ទី១ហៅថា "**សុនៃតិ**" (ការចេញនូវក្រឹត្យច្បាប់ ស្របតាមសីលធម៌ និងធម្មនុញ្ញជីវិត) និងទី២ ហៅថា "**ម្ទុទុគគ្តិ**" (ការប្រើប្រាស់អំណាចដ៏ទន់ភ្លន់)។ ស្លោកទី៣ អ្នកនិពន្ធកំណាព្យសំស្ក្រឹត បានប្រៀបធៀបលក្ខណៈសម្បត្តិ និងគុណសម្បត្តិរបស់ព្រះមហាក្សត្រអង្គនេះ ប្រដូចទៅនឹងព្រះសិវដែរ ពោល គឺស្តេចសាមន្តរដ្ឋទាំងឡាយគោរពក្រាបបង្គំវន្ទាចំពោះព្រះបាទាទាំងគូរបស់ទ្រង់។ ចូលដល់ស្លោកទី៤ គេបានពណ៌នាអំពីគុណសម្បត្តិរបស់ល្បីល្បាញគ្រប់ទិសទី ប្រៀបប្រដូចទៅនឹងរស្មីដួងចន្ទ្រាដែលមានពន្លឺភ្លឺថ្លាត្រចះត្រចង់។*

*មកដល់ស្លោកទី៥ គឺរៀបរាប់អំពីគុណសម្បត្តិរបស់ព្រះអង្គដដែល ដោយបង្ហាញឱ្យដឹងថា សេចក្តីក្លាហានរបស់ទ្រង់ ប្រៀបប្រដូចទៅនឹងព្រះស្រីនិវាស (ព្រះវិស្ណុ)។ គួរឱ្យចាប់អារម្មណ៍បំផុត នៅស្លោកទី៥ នេះ គេហៅព្រះនាមព្រះអង្គថា "**ឝ្រីឝានវម៌្មទេវ**" ឬសរសេរជាអក្សរខ្មែរទំនើបថា "**ស្រីសានវម៌្មទេវ**"។ នៅត្រង់ចំណុចនេះ ជាកស្តុតាងឱ្យយើងដឹងថា ការហៅព្រះនាមរបស់ព្រះមហាក្សត្រដោយភ្ជាប់ជាមួយពាក្យ "**ទេវ**" (ទេព) នៅខាងចុង ពុំមែនទើបតែមាននៅដើមសម័យអង្គរ ក្នុងរជ្ជកាលព្រះបាទឝ្រីជយវម៌្មទេវ (ទី២) (សិលាចារឹកព្រះធាតុព្រះស្រី ខេត្តត្បូងឃ្មុំ* K.103 / *គ.ស.ឆ្នាំ៧៧០ និងសិលាចារឹកល្បើកស្រុត ខេត្តក្រចេះ* K.134 / *គ.ស.ឆ្នាំ៧៨១) ដូចដែលអ្នកស្រាវជ្រាវមុនៗបានលើកឡើងនោះទេ។ ពោល គឺប្រពៃណីនេះ មានតាំងពីស.វ.ទី៧ ក្នុងរាជ្យព្រះបាទស្រីសានវម៌្ម (ទី១) មកម្ល៉េះ គ្រាន់តែគេមិនសូវនិយមខ្លាំង ឬប្រើប្រាស់ជាលក្ខណៈប្រព័ន្ធរដ្ឋបាលដូចនៅដើមសម័យអង្គរ (ចុងស.វ.ទី៨ - ១៣)។*

*ស្លោកទី៦ ពណ៌នាអំពី "**ព្រះឝ្រីគម្ភីរេឝ្វរ**" ដែលទំនងជាទេព (សិវលិង្គ) តម្កល់នៅប្រាសាទបល្ល័ង្ក។ ព្រះនាមទេពនេះ គេធ្លាប់ឃើញនៅក្នុងកំណត់ត្រាសិលាចារឹកជាច្រើននៅសម័យមុនអង្គរ (ស.វ.ទី៧-៨) ដូចជា នៅប្រាសាទក្បាលជ្រូក (ប្រាង្គ* N20-3 *សំបូរព្រៃគុក) ប្រាសាទក្តីអង្គ (ខេត្តព្រៃវែង) និងប្រាសាទអកយំ (ខេត្តសៀមរាប) ជាដើម។ មកដល់ស្លោកទី៧ អ្នកនិពន្ធបានចាប់ផ្តើមពណ៌អំពីការកសាងប្រតិមាដើម្បីបង្ហាញអំពីគុរុភក្តិត (សេចក្តីគោរពដឹងគុណគ្រូ)។ រីឯស្លោកទី៨ រៀបរាប់អំពីការប្រតិស្ឋានព្រះប្រតិមា "**ព្រះឝ្រីគម្ភីរេឝ្វរ**" ដោយព្រាហ្មណ៍ម្នាក់មាននាមថា "**វិទ្យាចន្ទ្រ**" ហើយស្លោកទី៩ ប្រតិស្ឋានព្រះប្រតិមានេះនៅក្នុងដែនដីឈ្មោះថា "**ចន្ទ្រទេស**"*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

*ដែលទំនងជាឈ្មោះដើមរបស់តំបន់នេះកាលពីសម័យបុរាណ។ ក្នុងការប្រតិស្ឋាននេះ មានបញ្ជាក់ថា ការតម្កល់ព្រះសម្ភុ (សិវ) គឺបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ (ខាងជើង) ហើយនេះជាព័ត៌មានដែលយើងអាចដឹងថា ប្រាសាទបល្ល័ង្កប្រហែលមានទ្វារចូល ឬបែរមុខទៅទិសខាងជើង។*

*ស្លោកទី១០ ដល់ទី១២ អ្នកនិពន្ធបានពណ៌នាអំពីព្រាហ្មណ៍ "**វិទ្យាចន្ទ្រ**" និងតង្វាយនូវសព្វទ្រព្យធន មានដូចជា គោ ដីស្រែ និងអ្នកបម្រើ ហើយបានបញ្ជាក់នូវបណ្ដាសាថា បើជនណាម្នាក់មានបំណងចង់បាន ឬរឹបអូសកាន់កាប់ដី ឬដណ្ដើមទ្រព្យសម្បត្តិទេវស្ថាននេះ នឹងត្រូវធ្លាក់ទៅរងនូវទារុណកម្មដ៏សែនវេទនាបំផុតនៅក្នុងស្ថាននរក រួមជាមួយកូន ចៅ និងញាតិសន្តានទាំងមូល។*

## អត្ថបទចារឹក និងសេចក្ដីប្រែ

១. ជយត្យនុបមេយេន្ទ្វ៉េ      រីកោងកូន្ទ្រកៃរវះ
អវាជិតនុកិវ៌ត្វ      មប្តកិយ៌្យស្យ តន្ត្រិវ។

**សេចក្ដីប្រែ៖** *ព្រះឦសាន (ព្រះសិវ) ដែលមានសេចក្ដីចម្រើន (ឫទ្ធិអំណាច) រកអ្វីប្រៀបផ្ទឹមពុំបាន ដែលមានចំណិតព្រះចន្ទ្រនៅលើព្រះសិរ ចូរមានជ័យជម្នះ! ព្រះអង្គទ្រង់គ្រប់គ្រងថែរក្សាលោកទាំងមូល តាមរយៈព្រះរូបកាយទាំងប្រាំបី (អស្ដមូត៌ិ) របស់ព្រះអង្គ ហាក់បីដូចជាខ្សែពិណដែលបង្កើតជាតន្ត្រីដ៏ពីរោះ។*

២. សុនៃតិម្ទុកក្តិត្យា      វិជិត្យាកេមកាត្រវានិ
ចរព្រៀតហានក្ត៌ាណា      សន្តតិស្រកាពេជីយះ។

**សេចក្ដីប្រែ៖** *ព្រះរាជាអង្គណា ដែលបានយកឈ្នះលើសត្រូវទាំងពួងឥតមានសេសសល់ ដោយប្រើប្រាស់នូវ**សុនៃតិ** (គឺនយោបាយដ៏ល្អ) និង**ម្ទុគត្តិ (ម្រឹទុសក្តិ)** (គឺអំណាចដ៏ទន់ភ្លន់)។ ព្រះអង្គបានធ្វើឱ្យផ្ទះសម្បែង (ក្នុងព្រះនគរ) មិនចាំបាច់មានរនាំងទ្វារបិទជិត (ព្រោះមានសុខសន្តិភាព) និងបានធ្វើឱ្យការបន្តពូជពង្សនៃប្រជានុរាស្ត្រ រីកចម្រើនទៅមុខជានិច្ចដោយគ្មានឧបសគ្គមករារាំងបានឡើយ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

៣.	ជិត្យាត្យយុគតាម្កោជំ	ជ២កោបរគោភិតមិ
	សជាវជតសាមន្ត	មៅលិបឡជសេវិតមិ។

**សេចក្តីប្រែ៖** *ព្រះបាទាទាំងគូរបស់ព្រះអង្គ ប្រៀបបានទៅនឹងផ្កាឈូកមាសរបស់ព្រះសិរ ដែលមានពន្លឺចែងចាំងស្អាតបាតទៅដោយកេសរ គឺព្រះនខា (ក្រចក)។ ព្រះបាទាទាំងគូនោះ តែងត្រូវបានស្តេចចំណុះ (សាមន្ត) និងសត្រូវទាំងឡាយ នាំគ្នាឱនក្បាលដាក់មកុដមកក្រាបបង្គំសំពះបម្រើនៅទៀបជើងជាដរាប។*

៤.	អមេយោគីត្តិ៍រវលា	ជិគន្តរិតិសប្បិ៍ណិ
	ឥន្ទោរិ .............	កវិភិយ៌្យស្យ គីត៌្យតេ។

**សេចក្តីប្រែ៖** *កេរ្តិ៍ឈ្មោះដ៏មហាសាល (របស់ព្រះអង្គ) បានរីកសាយកាយទៅសព្វទិសទី ហើយត្រូវបានពួកកវីទាំងឡាយពោលសរសើរ ប្រៀបប្រដូចជាពន្លឺព្រះចន្ទ្រ (ឥន្ទោរិ)........។*

៥.	ត្រិតាជវម៌្មទេវស្យ	ត្រីនិវាសស្យ វិក្រមាត
	យជ្វ..................ស្តស្យ	បុណ្យាជាំ ចាលជាយ យះ។

**សេចក្តីប្រែ៖** *តាមរយៈ**វិក្រមភាព** (គឺអំណាច) របស់ព្រះបាទ **ស្រីត្រៃលោក្យនាថវម៌្មទេព** ដែលទ្រង់ជា**ព្រះស្រីនិវាស** (គឺទីស្នាក់អាស្រ័យនៃសិរីសួស្តី=ព្រះវិស្ណុ) បូជាយញ្ញ (យជ្វ)........ អ្នកប្រាជ្ញរូបណា ដើម្បីអភិបាលរក្សានូវបុណ្យកុសលទាំងឡាយ........របស់ព្រះពជាអង្គនោះ។*

៦.	ត្រិកម៌្មវក្ត្រស្សេវ	ជកម្បិណាំ [ប្រ]មុខស្យ យះ
	តជ្ជាក្សក្សេម្បិ	...................កម្មិ៍សុ។

**សេចក្តីប្រែ៖** *អ្នកប្រាជ្ញរូបណា សូម្បីតែក្នុងកិច្ចការត្រួតពិនិត្យក្បួនខ្នាត និងការគ្រប់គ្រងដែនដី (សក្ការៈ) ទាំងឡាយ .............នៅក្នុងកិច្ចការទាំងឡាយ ទក្សិណាទានទាំងឡាយនៃព្រះ**ស្រីគម្ពីរស្វរៈ** ដែលជាប្រមុខ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

៧. តស្យាត្មនោ គុរុណាញ្ច ភវេ ភក្តិនិវន្ធនមិ
សធានុស្មុតិយោគក្ច យស្យេម្តញ្ជន្មជន្មសុ។

**សេចក្តីប្រែ៖** *ដោយមានភក្តីភាពចំពោះគ្រូទាំងឡាយរបស់ខ្លួន ដែលជាចំណងនៃការចងចាំ និងការប្រតិបត្តិយោគៈ ដែលជាបំណងប្រាថ្នារបស់រូបលោកជារៀងរាល់ជាតិ (ជន្មជន្មសុ) ផងនោះ។*

៨. តេន ............ជាម្នា វិទ្យាចន្ទ្រេន យជ្វនា
......................... វិធិនា សុប្រតិម្ទិបតះ។

**សេចក្តីប្រែ៖**............*(ព្រះប្រតិមា)*........ *ត្រូវបានប្រតិស្ឋានឡើងយ៉ាងល្អ តាមវិធីកម្មយ៉ាងត្រឹមត្រូវ ដោយអ្នកប្រាជ្ញ ដែលមាននាមថា* ***វិទ្យាចន្ទ្រ*** *ដែលជាបូជាចារ្យ (យជ្វនា) រូបនោះ*.............. ។

៩. យស្យតុ ចន្ទ្រទេគេស្មិន ស្ថាបិតោ ភគវានិយមិ
តេនោត្តរជិតាស្យេន ឝម្ភុជា ស្ថិរ[តាស្តុ]តាមិ។

**សេចក្តីប្រែ៖** *ព្រះភគវន្ត (ព្រះសិវ) អង្គនេះ ត្រូវបានប្រតិស្ឋាន នៅក្នុងដែនដី* ***ចន្ទ្រទេស*** *(ចន្ទ្រទេគ) នេះ។ សូមឱ្យព្រះសម្ភុ (ព្រះសិវ) ដែលត្រូវបានតម្កល់ ឱ្យបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ (ខាងជើង) ដោយអ្នកប្រាជ្ញ (វិទ្យាចន្ទ្រ) នោះ គង់ប្រថាប់នៅស្ថិតស្ថេរចីរកាលរៀងដរាបទៅចុះ!*

១០. តេជាយំ ភគវានីតោ យជ្វនា ក្ឫតវេជិនា
ស តស្មៃ ប្រតិវទ្ធ៌យ ធ្វេស្តត្តានន្ទកាមិ។

**សេចក្តីប្រែ៖** *ព្រះភគវន្តអង្គនេះ ត្រូវបាននាំមកតម្កល់ទុកដោយ (អ្នកប្រាជ្ញវិទ្យាចន្ទ្រ) ដែលជាអ្នកបូជា ដែលជាអ្នកមានធម៌កតញ្ញូដឹងគុណ។ សូមទេពអង្គនោះប្រទានពរនូវសេចក្តីចម្រុងចម្រើន និងសេចក្តីរីករាយ!*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

១១. តត្បរយ៍វ្រិជិស្ថិត្យៃ តេជាស្មៃយន្ធិវេជិតមិ
គោក្សេត្រជាសាជិជនំ សំហាត៌ុយស្តជិច្ឆតិ។

**សេចក្តីប្រែ៖** *ដើម្បីរក្សានូវពិធីបូជា គ្រឿងតង្វាយដែលលោក (វិទ្យាចន្ទ្រ) នោះ បានថ្វាយនូវទ្រព្យធន មានហ្វូងគោ ដីស្រែ និងខ្ញុំបម្រើជាដើម។ បុគ្គលណាដែលប្រាថ្នាចង់រឹបអូស ឬបំផ្លាញនូវទ្រព្យសម្បត្តិទាំងនោះ។*

១២. អវិជិយាតដាំឃោរាំ សំយាយាតិ ប្បុអាជមះ
សបុត្រទៅត្រសន្តាដោ ឯត៌្វយោជនលប្ទ[ព្វ]រាឌិ។

**សេចក្តីប្រែ៖** *បុរសដ៏ថោកទាបណា ដែលហ៊ានរំលោភបំពាន ឬលួចប្លន់យកទៅនូវទ្រព្យសម្បត្តិទាំងឡាយ ដែលគេបានចាត់ចែងថ្វាយទុកមកនេះ សូមឱ្យគេនោះព្រមទាំងកូន ចៅ និងញាតិសន្តានទាំងមូល នឹងត្រូវធ្លាក់ទៅរងនូវទារុណកម្មដ៏សែនវេទ្នាត់បំផុតនៅក្នុងនរក។*

*ជារួមមក សិលាចារឹករកឃើញទួលបល្ល័ង្ក ខេត្តកំពង់ឆ្នាំង ដែលកំពុងរក្សាទុកនៅវត្តសិរីរតនារាម (ហៅវត្តប្រណ្ហូក) គឺជាប្រភពពត៌មានដែលផ្តល់ឱ្យយើងដឹងអំពីគោលនយោបាយ និងគុណសម្បត្តិដ៏អស្ចារ្យរបស់ព្រះបាទស្រីសានវម៌្ម (ទី១)។ ជាពិសេស សិលាចារឹកនេះ គឺជាប្រភពដ៏ចាស់បំផុត (ស.វ.ទី៧) ដែលមានបង្ហាញព្រះនាមព្រះមហាក្សត្រ រួមជាមួយពាក្យ "**ទេវ**" នៅខាងចុង ពោល គឺ "ស្រីសានវម៌្មទេវ"។ ព្រមជាមួយនេះ ព័ត៌មានរបស់សិលាចារឹកបានឱ្យយើងស្គាល់អំពីព្រាហ្មណ៍ម្នាក់ឈ្មោះ "វិទ្យាចន្ទ្រ" ដែលជាស្ថាបនិកកសាងប្រាសាទ និងតម្កល់ព្រះប្រតិមា (ស្រីគម្ភីរេស្វរ) នៅដែនដី "ចន្ទ្រទេស" ពោល គឺទំនងជាទេពនៃប្រាសាទទួលបល្ល័ង្ក និងជាឈ្មោះដើមនៃតំបន់ប្រណ្ហូក កាលពីសម័យបុរាណ។*

*អត្ថបទដោយ៖ កំ វណ្ណាវ៉ា*



រូបលេខ១៖ ទិដ្ឋភាពទីតាំងទួលប្រាសាទបល្ល័ង្កសព្វថ្ងៃ (ទីតាំងរកឃើញសិលាចារឹក)



រូបលេខ២៖ ព្រះវិហារវត្តច្រណូក (ទីតាំងតម្កល់និងរក្សាទុកសិលាចារឹកទួលប្រាសាទបល្ល័ង្គ)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣ៈ ស្ថានភាពបច្ចុប្បន្ននៃសិលាចារឹកទួលប្រាសាទបល្ល័ង្គ K.1418

អត្ថបទដោយៈ កំ វណ្ណាក់



រូបលេខ៤៖ សំណៅផ្តិតសិលាចារឹកទួលប្រាសាទបល្ល័ង្គ K.1418
(ផ្តិតដោយ៖ កំ វណ្ណារ៉ា និង ហេង ដា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា